**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តបន្ទាយមានជ័យ**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត

លេខៈ......៤៩៥/១៧.....ឋគមលា

បន្ទាយមានជ័យ ថ្ងៃទី១១ ខែ ១១ ឆ្នាំ២០១៧

**ជម្រាបជូន**

- **លោកប្រធានអង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និងបរិស្ថាន**
- **លោកប្រធានអង្គការអភិវឌ្ឍន៍សង្គមបរិស្ថាន និងកសិកម្ម**

**កម្មវត្ថុ ៖** ស្តីពីការអនុញ្ញាត និងគាំទ្រការអនុវត្តគម្រោងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងសហគមន៍។

**យោង ៖** លិខិតលេខ ១០៥/១៧ អាសេដូ.បជ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ របស់អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និងបរិស្ថាន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធានអង្គការ** ជ្រាបថា ក្នុងឆ្នាំ ២០១៧ អង្គការទាំងពីរបានទទួលជំនួយ និងចុះកិច្ចព្រមព្រៀងជាមួយអង្គការការីតាសស្វីស ក្នុងការអនុវត្តគម្រោងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងសហគមន៍ ដែលមានរយៈពេល០៣ឆ្នាំ ចាប់ពីឆ្នាំ២០១៧ដល់២០២០ ក្នុងស្រុកស្វាយចេក មានឃុំតាផូ និងស្រុកព្រះនេត្រព្រះ មានឃុំទានកាំ និងឃុំទឹកជោរ របស់អង្គការ អា.សេ.ដូ (RCEDO) និងស្រុកមង្គលបូរី មានឃុំស្រះរាំង គោកបល្ល័ង របោះទឹក និងឃុំចំណោម របស់អង្គការ ស៊ីដូ (SEADO)។

សកម្មភាពគម្រោងមានដូចតទៅ៖ ១.ស្រាវជ្រាវអំពីប្រវត្តិគ្រោះមហន្តរាយ និងផែនទីទីទួលសុវត្ថិភាព ២.បង្កើនចំណេះដឹងអំពីការគ្រប់គ្រង និងដោះស្រាយធនធានទឹកក្នុងសហគមន៍ដល់អ្នកប្រើប្រាស់ទឹក ៣.ពង្រឹងបណ្តុះបណ្តាលដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ស្រុក អំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមបង្ការ ការឆ្លើយតប និងការស្តារឡើងវិញ និងការលើកកម្ពស់សន្តិសុខស្បៀង ៤.ផ្តល់ការគាំទ្រលើសេវាសង្គ្រោះបន្ទាន់ពេលមានគ្រោះមហន្តរាយ ៥.ធ្វើផែនការ និងអនុវត្តសកម្មភាពទៅលើតម្រូវការរបស់សហគមន៍ក្នុងការត្រៀមបង្ការ និងឆ្លើយតប ៦.អប់រំផ្សព្វផ្សាយចំណេះដឹងអំពីការការពារធនធានធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន និង ៧.អប់រំផ្សព្វផ្សាយចំណេះដឹងដល់សិស្សានុសិស្ស ស្តីពីទឹកស្អាត សុខភាព និងអនាម័យផ្ទាល់ខ្លួន។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** ជ្រាប និងចាត់ចែងអនុវត្តគម្រោងនេះប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាព។

សូម **លោកប្រធាន** ទទួលនូវការរាប់អានអំពីខ្ញុំ។

**អភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត**

**សួន បវរ**

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋាននៃ គ.ជ.គ.ម
- ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ
- **"ដើម្បីគោរពជូនជ្រាប"**
- រដ្ឋបាលស្រុកស្វាយចេក មង្គលបូរី និង រដ្ឋបាលស្រុកព្រះនេត្រព្រះ **"ដើម្បីសហការអនុវត្ត"**
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈ ផ្លូវជាតិលេខ៥ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ-ទូរសារ
(Phone-Fax) ០៥៤ ៧១០០៦២ Email: banteaymeanchey1@gmail.com ,